# សេចក្តីថ្លែងការណ៍រួម
# ការបញ្ចប់និទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាននៅកម្ពុជា

រាជធានីភ្នំពេញ ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣

ក្នុងទិវាអន្តរជាតិដើម្បីបញ្ចប់និទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាន យើងខ្ញុំជាអង្គការសង្គមស៊ីវិលដែលមានរាយនាមដូចខាងក្រោម សូមអំពាវនាវដល់រដ្ឋាភិបាលកម្ពុជា ចាត់វិធានការឱ្យបានឆាប់រហ័ស និងជាក់លាក់ ដើម្បីធានានូវការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព ឯករាជ្យ និងតម្លាភាព ទៅលើឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ដែលបានប្រព្រឹត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ចាប់តាំងពីឆ្នាំ១៩៩៤ យ៉ាងហោចណាស់អ្នកសារព័ត៌មានចំនួន១៥នាក់ត្រូវបានសម្លាប់នៅក្នុងប្រទេសកម្ពុជា។ ក្នុងចំណោមនោះ អ្នកសារព័ត៌មានចំនួន១២នាក់បានរាយការណ៍អំពីបញ្ហារសើបនៅពេលពួកគេត្រូវបានសម្លាប់។ ទោះបីជាយ៉ាងណាក៏ដោយ គ្មានជនល្មើសណាម្នាក់ត្រូវបាននាំមកផ្តន្ទាទោសចំពោះករណីទាំងអស់នេះទេ។

និទណ្ឌភាពចំពោះបទឧក្រិដ្ឋបែបនេះ មិនមែនកើតមានចំពោះតែទៅលើការវាយប្រហារលើអ្នកសារព័ត៌មានប៉ុណ្ណោះទេ។ កង្វះខាតនូវការស៊ើបអង្កេត និងនីតិវិធីព្រហ្មទណ្ឌត្រឹមត្រូវចំពោះឃាតកម្មលើសកម្មជនបរិស្ថាន លោក ឈុត វុទ្ធី សកម្មជនសហជីព លោក ជា វិជ្ជា និងលោក រស់ សុវណ្ណារ៉េត អ្នកវិភាគនយោបាយលោកបណ្ឌិត កែម ឡី កាន់តែបង្ហាញពីការរីករាលដាលនៃវប្បធម៌និទណ្ឌភាពដែលមាននៅក្នុងប្រទេសកម្ពុជាបន្ថែមទៀត។ ករណីរៀបរាប់ខាងលើគ្រាន់តែជាផ្នែកមួយនៃករណីជាច្រើនទៀតនៃការរំលោភបំពានលើអ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស សមាជិកនយោបាយជំទាស់ សហជីព និងសកម្មជនផ្សេងៗទៀតដែលករណីពួកគេមិនត្រូវបានដោះស្រាយពីសំណាក់ស្ថាប័នដែលមានតួនាទីការពារសិទ្ធិមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា។

ការឃាយឺ និងឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាននៅតែជាក្តីបារម្ភនៅឆ្នាំ២០២៣នេះ។ យោងតាមសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា) អ្នកសារព័ត៌មានចំនួន៣០នាក់រងការឃាយឺក្នុងរយៈពេល១០ខែចុងក្រោយនេះ (ពីខែមករា ដល់ខែតុលា ឆ្នាំ២០២៣)។ ក្នុងចំណោមអ្នកសារព័ត៌មានទាំង៣០នាក់នេះ ២៣នាក់ទទួលរងអំពើហិង្សា និងការគំរាមកំហែង ៤នាក់ប្រឈមនឹងការឃាយឺតាមផ្លូវតុលាការ ២នាក់ត្រូវបានឃាត់ខ្លួនដើម្បីសួរចម្លើយ។ បន្ថែមពីនេះ អាជ្ញាបណ្ណសារព័ត៌មានចំនួន៥ត្រូវបានដកហូត។ ជាលទ្ធផល អង្គការអ្នកសារព័ត៌មានគ្មានព្រំដែនបានចាត់ថ្នាក់ប្រទេសកម្ពុជានៅលេខ១៤៧ ក្នុងចំណោម១៨០ប្រទេសនៅក្នុងឆ្នាំ២០២៣ ដូច្នេះប្រទេសកម្ពុជាបានធ្លាក់៥លេខបើប្រៀបធៀបទៅនឹងឆ្នាំ២០២២។

ការដៅមុខសញ្ញាលើអ្នកសារព័ត៌មាន ជាពិសេសអ្នកដែលកំពុងរាយការណ៍លើប្រធានបទសិទ្ធិមនុស្សធ្វើឱ្យប៉ះពាល់ដល់សេរីភាពខាងការបញ្ចេញមតិនិងសារព័ត៌មាន បង្កជាការគំរាមកំហែងដល់ការទទួលបានព័ត៌មានរបស់សាធារណជន។ ការឃាយឺ និងការធ្វើទុក្ខបុកម្នេញនេះកាន់តែបង្កផលលំបាកថែមទៀតក្នុងការនាំ

ឱ្យបុគ្គលមានអំណាចទទួលខុសត្រូវចំពោះកំហុសរបស់ខ្លួន។ នៅពេលដែលអាជ្ញាធរមិនបានធ្វើការស៊ើបអង្កេតត្រឹមត្រូវ និងផ្តន្ទាទោសអ្នកប្រព្រឹត្តឧក្រិដ្ឋកម្មលើអ្នកសារព័ត៌មាន ជាសារមួយបង្ហាញថាឧក្រិដ្ឋកម្មបែបនេះត្រូវបានអនុញ្ញាត។

ដូច្នេះ យើងខ្ញុំសូមអំពាវនាវដល់រដ្ឋាភិបាលឱ្យធ្វើការស៊ើបអង្កេតដោយឯករាជ្យទៅលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស។ ការស៊ើបអង្កេតទាំងនេះត្រូវតែប្រព្រឹត្តទៅដោយឆាប់រហ័ស និងស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលរួមបញ្ចូលទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ផែនការសកម្មភាពនៃអង្គការសហប្រជាជាតិស្តីពីសុវត្ថិភាពរបស់អ្នកសារព័ត៌មាន និងបញ្ហានិទណ្ឌភាព និងគោលការណ៍សម្រាប់ការពារ និងលើកកម្ពស់សិទ្ធិមនុស្សតាមរយៈសកម្មភាពប្រឆាំងនិទណ្ឌភាព ដែលក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិបានធ្វើបច្ចុប្បន្នភាព។

យើងខ្ញុំសូមទាមទារយុត្តិធម៌សម្រាប់អ្នកទាំងឡាយណាដែលសិទ្ធិរបស់គេមិនត្រូវបានអើពើ។ រដ្ឋាភិបាលកម្ពុជាត្រូវតែថ្កោលទោស និងបញ្ចប់នូវនិទណ្ឌភាពចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស។

**សេចក្តីថ្លែងការណ៍នេះចូលរួមគាំទ្រដោយ៖**

១.សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)

២.មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់)

៣.មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ស.ស.ម.ក)

៤.មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ(CCIM)

៥.សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា(សមាគមអាដហុក)

៦.សមាគមកម្មករកម្ពុជាសេដ្ឋកិច្ចក្រៅប្រព័ន្ធ (CIWA)

៧.សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស(លីកាដូ)

៨.សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា (CTWUF)

៩.សហព័ន្ធសហជីពសេរីឯករាជ្យ (FUFI)

១០.សហព័ន្ធសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា (FTUWKC)

១១.សហព័ន្ធសហជីពឯករាជ្យ (INTUFE)

១២.សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនកាស៊ីណូ ណាហ្គាវើលដ៍ (LRSU)

១៣.អង្គការសមាគមជាងត្នោត(សជត)

១៤.Association Journalists Timor Leste (AJTL)

១៥.The Alliance of Independent Journalists (AJI), Indonesia

๑๖.Centre for Independent Journalism (CIJ)

๑๗.Gerakan Media Merdeka (Geramm)- Malaysia

๑๘.The International Federation of Journalists (IFJ)

๑๙.Prachatai, Thailand

๒๐.Reporters Without Borders (RSF)